# ឃ្លាំមើលសភា និងតំណាងរាស្ត្រ

របាយការណ៍ឆ្នាំទី៣ លេខ ១៤ | នីតិកាលទី ៤ | ខែមករា-មីនា ២០១១

រដ្ឋសភាជាតិក្នុងខែមករា ដល់ខែមីនា ឆ្នាំ២០១១ គឺជារយៈពេលសម្រាកបន្ទាប់ពីសម័យប្រជុំលើកទី ៥ ដែលស្ថិតនៅក្នុងរយៈពេលពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០១០។

ក្នុងរយៈពេលសម្រាកនេះ រដ្ឋសភាមិនបានធ្វើការប្រជុំពេញអង្គនោះទេ។ ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្របានយកពេលនោះចុះមូលដ្ឋានបានច្រើនជាងខែមុនៗ។

## ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ៖

- គណបក្ស ប្រជាជនកម្ពុជា
- គណបក្ស សម រង្ស៊ី
- គណបក្ស សិទ្ធិមនុស្ស
- គណបក្ស ហ៊្វុនស៊ិនប៉ិច
- គណបក្ស នរោត្តម រណឫទ្ធិ

តាមទិន្នន័យខុមហ្វ្រែលដែលទទួលបានបង្ហាញថា ក្នុងរយៈពេល៣ខែនេះ (មករា ដល់មីនា២០១១) អ្នកតំណាងរាស្ត្របានចុះមូលដ្ឋានច្រើនជាងត្រីមាសមុន (តុលា-ធ្នូ ២០១០)។

ក្នុងរយៈពេលនេះ មានអ្នកតំណាងរាស្ត្រយ៉ាងតិច៨៥រូប (ឬ៦៩% នៃអ្នកតំណាងរាស្ត្រសរុប១២៣រូប) បានចុះមូលដ្ឋានសរុបបានយ៉ាងតិច៦៣៨លើក គឺកើនឡើងជាងរយៈពេល៣ខែមុន ប្រមាណ៥៣% (ពីខែតុលា ដល់ធ្នូ ២០១០ អ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានសរុប៤១៦លើក)។ ចំណែកចំនួនអ្នកតំណាងរាស្ត្រ ដែលចុះមូលដ្ឋានក៏មានការកើនឡើងដល់៨៥រូប គឺកើនឡើងជាង៣ខែមុនប្រមាណ១៣% (ពីខែតុលា ដល់ធ្នូ២០១០មានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានតែ៧៥រូប)។

ទោះបីយ៉ាងណា ខុមហ្វ្រែលមិន បានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅក្នុងមណ្ឌលចំនួន៣ គឺ មណ្ឌលកែប មណ្ឌលប៉ៃលិន និងមណ្ឌល មណ្ឌលគីរីនោះទេ។

***<u>ក្រាហ្វិទី១៖ ភាគរយកំណើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សចន្លោះពីខែមករា-មីនា ២០១១ ធៀបនឹងតុលា-ធ្នូ ២០១០</u>***




តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា បានបង្កើនការចុះមូលដ្ឋានរបស់ខ្លួន រហូតដល់៤៦៥លើកក្នុងត្រីមាសនេះ គឺលើសត្រីមាសមុនប្រមាណ៦៣%( បីខែមុន អ្នកតំណាងរាស្ត្រគណបក្សនេះ ចុះមូលដ្ឋានបាន ២៨៤លើក) និងចំនួនតំណាងរាស្ត្របានកើនពី៥៥រូប ដល់៦៥រូប។

ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ទាំង៣រូប ក៏បានបង្កើនការចុះមូលដ្ឋានរបស់ខ្លួនរហូតដល់៦៣លើក គឺកើនឡើងប្រមាណ ៤ដងធៀបនឹង៣ខែមុន (ពីតុលា ដល់ធ្នូ ២០១០ អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចុះមូលដ្ឋានបា១៣ លើក)។

អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី និងហ្វ៊ុនស៊ិនប៉ិចមានការធ្លាក់ចុះ ហើយតំណាងរាស្ត្រគណបក្ស នរោត្តម រណឫទ្ធិ គឺចុះមូលដ្ឋានបានដូចនឹងត្រីមាសមុនដែរ។

ក្នុងចំណោមតំណាងរាស្ត្រទាំង៨៥រូបដែលបានចុះមូលដ្ឋាន មានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា សរុប៦៥រូប (ស្មើនឹង៧២%នៃតំណាងរាស្ត្រគណបក្សនេះសរុប៩០រូប)។ តំណាងរាស្ត្រគណបក្ស សមរង្ស៊ីសរុប១៤រូប (ស្មើនឹង៥៤%នៃតំណាងរាស្ត្រគណបក្សនេះសរុប ២៦រូប)។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៣រូប និងតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចទាំង២រូបបានចុះមូលដ្ឋានទាំងអស់។ តំណាងរាស្ត្រគណបក្ស នរោត្តម រណឫទ្ធិ១រូប ក្នុងចំណោម២រូបបានចុះមូលដ្ឋាន។

បើគិតជាចំនួនចុះមូលដ្ឋានសរុបតាមគណបក្ស តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះមូលដ្ឋានច្រើនជាងគេ ដោយសារគណបក្សទាំងពីរនេះមានអ្នកតំណាងរាស្ត្រច្រើន ដែលក្នុងនោះគណបក្សប្រជាជនកម្ពុជា៤៦៥លើក និងគណបក្សសមរង្ស៊ីបាន៩៤លើក។ តែតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស៦៣លើក គណបក្សហ្វ៊ុនស៊ិនប៉ិចបាន១៣លើក និងគណបក្សនរោត្តមរណឫទ្ធិបាន៣លើក។

ទោះបីយ៉ាងណា បើគិតជាមធ្យមនៃតំណាងរាស្ត្រម្នាក់ៗដែលចុះមូលដ្ឋានតាមគណបក្សវិញឃើញថា តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សជាមធ្យមចុះបានច្រើនជាងគេ ដោយក្នុងតំណាងរាស្ត្រមួយរូបចុះមូលដ្ឋានជាមធ្យមបាន២១លើក តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាមធ្យមបាន៨លើក តំណាងរាស្ត្រសមរង្ស៊ីជាមធ្យមម្នាក់បាន៧លើក គណបក្សហ្វ៊ុនស៊ិនប៉ិច៧លើកក្នុង១រូប និងគណបក្សនរោត្តម រណឫទ្ធិ៣លើក។

***<u>ក្រាហ្វិកទី២៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្ស</u>***




បើគិតតាមសមាមាត្រ ភាគរយនៃតំណាងរាស្ត្រក្នុងសភាតាមគណបក្ស និងភាគរយនៃការចុះមូលដ្ឋានសរុបតាមគណបក្សបង្ហាញថាចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា នរោត្តម រណឫទ្ធិ និងហ្វ៊ុនស៊ិនប៉ិច គឺស្មើរតែសមាមាត្រទៅនឹងអាសនៈសភា ដែលគណបក្សនីមួយៗទទួលបានក្នុងរដ្ឋសភា។ គណបក្សប្រជាជនកម្ពុជាដែលមានអាសនៈសរុប៧៣%នៅរដ្ឋសភា ចុះមូលដ្ឋានបាន៧២%នៃការចុះមូលដ្ឋានសរុប និងតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច និងនរោត្តម រណឫទ្ធិ ដែលរួមគ្នាមានអាសនៈ៣%ក្នុងរដ្ឋសភា ក៏ចុះមូលដ្ឋានបាន៣%ដែរ។

ចំណែកអ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ី ដែលមានអាសនៈ២១%នៅសភា បានចុះមូលដ្ឋានប្រមាណ១៥%។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សដែលមានអាសនៈប្រមាណ៣% បានចុះមូលដ្ឋានបានប្រមាណ១០%។

*តារាងទី ១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស*

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ៦៣៨លើក របស់តំណាងរាស្ត្រទាំង ៨៥រូប** | **គណបក្សនយោបាយ** | | | | | សរុបគោលបំណង |
|---|---|---|---|---|---|---|
| | **៦៥រូប** | **១៤ រូប** | **៣ រូប** | **២ រូប** | **១ រូប** | |
| សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ២៥២ (៥៤%) | ៤៥ (៤៩%) | ៥៦ (៨៩%) | 0 | ១ (៣៣%) | ៣៥៤ (៥៦%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ៦៧ (១៤%) | ៣១ (៣៣%) | ៦ (១០%) | 0 | ១ (៣៣%) | ១០៥ (១៦%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ១៣៤ (២៩%) | ៤ (៤%) | 0 | ១៣ (១០០%) | 0 | ១៥១ (២៤%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៧ (២%) | ៦ (៦%) | ១ (១%) | 0 | ១ (៣៣%) | ១៥ (២%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ៥ (១%) | ៨ (៨%) | 0 | 0 | 0 | ១៣ (២%) |
| **សរុបគោលបំណងតាមគណបក្ស** | **៤៦៥** | **៩៤** | **៦៣** | **១៣** | **៣** | **៦៣៨** |

តារាងទី១បានបង្ហាញថា ការចុះមូលដ្ឋានភាគច្រើនរបស់អ្នកតំណាងរាស្ត្រ គឺផ្តោតទៅលើគោលបំណងសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាដែលសរុបមានរហូតដល់៣៥៤លើក (ឬ៥៦%នៃការចុះមូលដ្ឋានសរុប)។ ការចុះអមដំណើរថ្នាក់ដឹកនាំ២៤%។ ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន១៦%។ ដោយឡែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានតិចតួចប៉ុណ្ណោះ សរុបបាន២៨លើក (៤% នៃការចុះមូលដ្ឋានសរុប)។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៦៥រូប ចុះបានសរុប៤៦៥លើក)៖** ជាសរុប តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានច្រើនជាងគណបក្សផ្សេងៗ។ ក្នុងនោះ ៨៣%នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺក្នុងគោលបំណងសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធផលនានា(៥៤%) និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន (២៩%)។

អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាក៏ចុះមូលដ្ឋាន ក្នុងគោលបំណងពង្រឹងគណបក្សរបស់ខ្លួន ដែលសរុបមាន១៤%។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈរួមគ្នាមាន៣% (១២លើក)។ ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជា៖

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រ ញឹម វណ្ណដា មណ្ឌលព្រៃវែង បានអញ្ជើញចុះសម្ពោធសាលារៀនឲ្យប្រើប្រាស់នៅវត្តត្នោតគង់កើត ឃុំគោកគង់លិច ស្រុកកញ្ជ្រៀច និងមានការចែកអំណោយផងដែរ។ អ្នកតំណាងរាស្ត្រកែវ សូសាក់ មណ្ឌលកំពង់ឆ្នាំង នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១១ បានចុះទៅសំរបសំរួល ដោះស្រាយទំនាស់ដីធ្លីនៅឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង តែការធ្វើអន្តរាគមន៍នោះមិនទាន់បានជោគជ័យទេ ដោយភាគីម្ខាងមិនយល់ព្រមនូវការសំរបសំរួលដោះស្រាយ

នោះ។ អ្នកតំណាងរាស្ត្រ ហូ ណូន មណ្ឌលកណ្តាលបានចុះអមដំណើរសម្តេចហេង សំរិន ប្រធានរដ្ឋសភាដែលបានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលភូមិអភិវឌ្ឍន៍ ស្រុកពញាក្រែក ខេត្តកំពង់ចាម នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី (១៨រូប ចុះសរុបបាន៩៨លើក)៖** ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ មកពីគណបក្សសមរង្ស៊ីបានផ្តោតខ្លាំងលើការសួរសុខទុក្ខ(៤៩% ឬ៤៥លើកនៃការចុះមូលដ្ឋានរបស់គណបក្សនេះសរុប) ការពង្រឹងបណ្តាញគណបក្ស (ស្មើនឹង៣៣% ឬ៣១លើក) និងការចូលរួមវេទិកាសាធារណៈ និងការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍សរុបរួមមាន១៤%(១៤លើក)។ ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្ស សមរង្ស៊ី ក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំមាន៤% (៤លើក)។

ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី មានដូចជា៖

អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ នុត រំដួល នៅថ្ងៃទី១៣ខែមីនា ឆ្នាំ២០១១ បានចុះអន្តរាគមន៍ជួយប្រជាពលរដ្ឋចំនួន៦៨គ្រួសារ ដែលមានទំនាស់ដីធ្លីជាមួយក្រុមហ៊ុនលោកលីយ៉ុងផាត់ នៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ អ្នកតំណាងរាស្ត្រ មណ្ឌលសៀមរាប កែ សុវណ្ណរតន៍ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១១ អញ្ជើញចុះទៅឃុំត្រញ៉ឹងស្រែ ស្រុកមេសាង ខេត្តព្រៃវែង គោលបំណងរៀបចំរចនាសម្ព័ន្ធសកម្មជនស្រុកថ្មី។ អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ យន្ត ថារ៉ូ បានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋនៅឃុំប៉ោយប៉ែត ស្រុកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស (៣រូប ចុះបានសរុប៦៣លើក)៖** តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្តោតលើចុះសួរសុខទុក្ខ ចែកអំណោយដែលមានដល់ទៅ៨៩%(៥៦លើក)នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ។ ការចុះពង្រឹងគណបក្សមាន១០% (៦លើក) និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈ១% (១លើក)។

គណៈកម្មាធិការខុមហ្វ្រែល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួននោះទេ។

ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្ស សិទ្ធិមនុស្សមានដូចជា៖

អ្នកតំណាងរាស្ត្រ គឹម សុខា មណ្ឌលកំពង់ចាមថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ បានអញ្ជើញចុះទៅភូមិព្រៃកក្រូច ឃុំព្រៃកតាសរ ស្រុកពារាំង ខេត្តព្រៃវែងដើម្បីសំណេះសំណាលសួរសុខទុក្ខ ប្រជាពលរដ្ឋប្រមាណ៧០០នាក់។ ចំណែកអ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ បានអញ្ជើញចូលរួមវេទិកាសិទ្ធិមនុស្សរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅស្រុកសណ្តាន់ ខេត្តកំពង់ធំ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច (២រូប ចុះបានសរុប ១៣លើក)៖** អ្នកតំណាងរាស្ត្រគណបក្សនេះទាំងពីររូបសុទ្ធតែបានចុះមូលដ្ឋានសរុប១៣លើក ដោយផ្តោតទាំងស្រុងលើការចុះអមដំណើរថ្នាក់ដឹកនាំ (ស្មើនឹង១០០% នៃការចុះមូលដ្ឋានសរុប)។ ដូចជាកាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ តំណាងរាស្ត្រ ញឹក ប៊ុនឆៃ បានចុះអមដំណើរសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីអញ្ជើញជាអធិបតីភាពក្នុងពិធីប្រគល់សញ្ញាប័ត្រជូនដល់គរុនិស្សិតបច្ចេកទេសកំរិតមូលដ្ឋាន កំរិតឧត្តម និងនិស្សិតបច្ចេកវិទ្យាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ បច្ចេកទេសថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

គណៈកម្មាធិការខុមហ្វ្រែល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គណបក្សហ៊្វុនស៊ិនប៉ិចក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ ការចូលរួមវេទិកាសាធារណៈ ការសួរសុខទុក្ខ ចែកអំណោយ និងការចុះមូលដ្ឋានដើម្បីពង្រឹងគណបក្សរបស់ខ្លួននោះទេ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនរោត្តម រណឫទ្ធិ (១រូប ចុះបាន៣លើក)៖** ខុមហ្វ្រែលទទួលបានព័ត៌មានតែការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ សៅ រ៉ានី មណ្ឌលព្រៃវែងប៉ុណ្ណោះសម្រាប់គណបក្សនេះ ដែលបានចុះមូលដ្ឋាន

សរុប៣លើក ក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាជន (១លើក) ចូលរួមវេទិកា (១លើក) និងពង្រឹងបណ្តាញគណបក្ស (១លើក)។ អ្នកតំណាងរាស្ត្រ សៅ រ៉ានី កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ បានអញ្ជើញចុះសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយសំភារៈប្រគល់ជូនកងកំលាំងខេមរភូមិន្ទនៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១១ អ្នកតំណាងរាស្ត្ររូបនេះបានអញ្ជើញចូលរួមសិក្ខាសាលារបស់អង្គការ អ៊ិន ឌី អាយ ដែលមានអ្នកចូលរួមប្រហែល៤០០នាក់នៅភូមិស្វាយទាប ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

***<u>តារាងទី ២៖ អ្នកតំណាងរាស្ត្រដែលចុះមូលដ្ឋានច្រើនជាងគេ៥រូបក្នុងចន្លោះពីខែមករា-មីនា ២០១១</u>***

| ល.រ. | ឈ្មោះ តំណាងរាស្ត្រ | គណបក្ស | គោលបំណង | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹងបក្ស | វេទិកា | អមដំណើរ | |
| ១ | យន្ត ថារូ | | ០ | ៣៣ | ០ | ១ | ០ | ៣៤ |
| ២ | ញឹម វណ្ណដា | | ០ | ២៥ | ៣ | ០ | ៤ | ៣២ |
| ៣ | កឹម សុខា | | ០ | ៣០ | ១ | ០ | ០ | ៣១ |
| ៤ | អ៊ូ ច័ន្ទឫទ្ធិ | | ០ | ១៧ | ១ | ០ | ០ | ២២ |
| ៥ | ប៉ាល់ សំអឿន | | ១ | ៩ | ៦ | ០ | ៥ | ២១ |

គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស សុទ្ធតែមានតំណាងរាស្ត្រដែលស្ថិតក្នុងចំណោមអ្នកចុះមូលដ្ឋានបានច្រើនជាងគេ។

គណបក្សសម រង្ស៊ី មានតំណាងរាស្ត្រ យន្ត ថារូ មណ្ឌលបន្ទាយមានជ័យបានចុះមូលដ្ឋានច្រើនជាងគេដល់៣៤លើក និងតាមដោយអ្នកតំណាងរាស្ត្រ ញឹម វណ្ណដា គណបក្សប្រជាជនកម្ពុជាមណ្ឌលព្រៃវែងបានចុះមូលដ្ឋានសរុប៣២លើក និងអ្នកតំណាងរាស្ត្រ កឹម សុខា មណ្ឌលកំពង់ចាម មកពីគណបក្សសិទ្ធិមនុស្សបានចុះមូលដ្ឋានសរុប៣១លើក។

អ្នកតំណាងរាស្ត្រទាំង៥រូប ភាគច្រើនចុះមូលដ្ឋានក្នុងគោលបំណងសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធផលនានា។ ដោយឡែកក្នុងចំណោមតំណាងរាស្ត្រទាំង៥រូប មានតែតំណាងរាស្ត្រ ប៉ាល់ សំអឿន ដែលបានចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍១ដង។

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### វិវាទឬជិវិវាទក្នុងការផ្តល់អភ័យឯកសិទ្ធិ

នៅដើមឆ្នាំ២០១១នេះ មានព្រឹត្តិការណ៍សំខាន់ចំនួន២ដែលបានកើតឡើង និងអាចមានឥទ្ធិពលអវិជ្ជមានដល់ការបំពេញតួនាទីរបស់អ្នកតំណាងរាស្ត្រគឺការបាត់បង់អភ័យឯកសិទ្ធជាង២ឆ្នាំ (ជិតពាក់កណ្តាលអាណត្តិ) និងការបាត់បង់សមាជិកភាពសភា ដោយសារការបញ្ចេញមតិ និងការបំពេញតួនាទី។

អ្នកតំណាងរាស្ត្រ មូរ សុខហួរ ដែលត្រូវតុលាការកាត់ក្តីឲ្យចាញ់នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងបណ្តឹងបរិហារកេរ្តិ៍ដែលកើតឡើងដោយការបញ្ចេញមតិ បានបំពេញទោសរបស់ខ្លួន ដោយសងជម្ងឺចិត្តជាទឹកប្រាក់ប្រមាណ១៦លានរៀលដល់លោកនាយករដ្ឋមន្ត្រី និងរដ្ឋាភិបាលកាលពីចុងខែតុលា ឆ្នាំ២០១០។

អ្នកតំណាងរាស្ត្ររូបនេះរំពឹងថា ខ្លួននឹងបានអភ័យឯកសិទ្ធិសភារបស់ខ្លួនវិញដែលបានព្យួរជាង១ឆ្នាំ (តាំងពីខែមិថុនា ឆ្នាំ២០០៩) បន្ទាប់ពីខ្លួនបានអនុវត្តទោសរួច។

នៅដើមខែមករា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រ មូរ សុខហួរ បានទាមទារសភាឲ្យផ្តល់អភ័យឯកសិទ្ធសភារបស់ខ្លួនឡើងវិញ។ មុននឹងមានការឆ្លើយតបជាផ្លូវការ ថ្នាក់ដឹកនាំរដ្ឋសភា និងស្ថាប័នតុលាការ និងក្រសួងយុត្តិធម៌របស់រាជរដ្ឋាភិបាលបានថ្លែងជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយលើកដាក់គ្នា ពីអ្នកទទួលខុសត្រូវក្នុងបែបបទផ្តល់អភ័យឯកសិទ្ធិ ដល់អ្នកតំណារាស្ត្រនេះវិញ។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាដែលជាស្ថាប័នដឹកនាំរដ្ឋសភា អ្នកតំណាងរាស្ត្រ ជាម យៀបត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីថា រដ្ឋសភាជាតិត្រូវការសំណើរបស់ចៅក្រម និងក្រសួងយុត្តិធម៌ ទើបអាចរដ្ឋសភាផ្តល់អភ័យឯកសិទ្ធិឲ្យលោកស្រី មូរ សុខហួរ ហើយសាមីខ្លួនគាត់ទេសួរតុលាការ។

ដោយឡែករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម អង្គ វង្សវឌ្ឍនា ត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីដែរថា " រដ្ឋសភាត្រូវសរសេរលិខិតមកក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌កំពុងរង់ចាំលិខិតពីរដ្ឋសភា"។

ទោះបីយ៉ាងណាលោក សុក សំអឿន ប្រធានអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានត្រូវប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីថា «ក្រសួងយុត្តិធម៌មានសិទ្ធិ និងសមត្ថកិច្ចធ្វើលិខិតជូនដំណឹងទៅរដ្ឋសភាអំពីករណីរបស់លោកស្រីមូរ សុខហួរ»។

អ្នកតំណាងរាស្ត្រជាម យៀបក៏បានថ្លែងដែរថា កន្លងមកដូចករណីអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ គឺរង់ចាំលិខិតពីក្រសួងយុត្តិធម៌។

ក្រោយមកទៀត រដ្ឋសភាក៏បានធ្វើការឆ្លើយតបជាផ្លូវការ បដិសេធសំណើផ្តល់អភ័យឯកសិទ្ធិក្រោមហេតុផលថា អ្នកតំណាងរាស្ត្រពុំទាន់បានទទួលនីតិសម្បទាពេញលេញពីតុលាការនៅឡើយដែលត្រូវការរយៈពេល១ឆ្នាំ បន្ទាប់ពីការអនុវត្តន៍ទោសរួចហើយ គឺនៅចុងឆ្នាំ២០១១។

អ្នកតំណាងរាស្ត្រ មូរ សុខហួរ ត្រូវបានដកអភ័យឯកសិទ្ធិកាលពីខែ មិថុនា ឆ្នាំ២០០៩ ដូច្នេះអ្នកតំណាងរាស្ត្ររូបនេះត្រូវបាត់បង់អភ័យឯកសិទ្ធិសភារបស់ខ្លួនជាង២ឆ្នាំ ដោយសារតែការបញ្ចេញមតិដែលជានាដោយរដ្ឋធម្មនុញ្ញ។

## ការបញ្ចប់សមាជិកភាព និងបុព្វសិទ្ធិអ្នកតំណាងរាស្ត្រ

អ្នកតំណាងរាស្ត្រសមរង្ស៊ីបានបាត់បង់សមាជិកភាព និងបុព្វសិទ្ធិ បន្ទាប់ពីការសម្រេចរបស់តុលាការកំពូលនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ថា ឲ្យមានទោស និងឲ្យជាប់ពន្ធនាគារក្នុងបណ្តឹងដែលធ្វើឡើងដោយរាជរដ្ឋាភិបាលប្រឆាំងអ្នកតំណាងរាស្ត្ររូបនេះ (នៅពេលអ្នកតំណាងរាស្ត្ររូបនេះបានចុះអន្តរាគមន៍ជួយប្រជាពលរដ្ឋដែលអះអាងថា បាត់បង់ដីដោយសារការបោះបង្គោលព្រំដែនជាមួយវៀតណាម ហើយឈានទៅដល់ការដកបង្គោលតំរុយព្រំដែន) និងលិខិតរបស់ប្រធានរដ្ឋសភាចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ ស្តីពីការបញ្ចប់សិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពរបស់អ្នកតំណាងរាស្ត្ររូបនេះ។

បើគ្មានការដោះស្រាយនយោបាយ ឯកឧត្តម សម រង្ស៊ីនឹងមិនមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យបានទេ នៅឆ្នាំបោះឆ្នោត២០១៣ខាងមុខ។

ករណីនេះនាំមកនូវវិវាទប្បដិវាទក្នុងនីតិកាល និងដំណើរការតាំងពីការដកអភ័យឯកសិទ្ធិ ការរកភស្តុតាង និងដំណើរការកាត់សេចក្តីរបស់តុលាការ។

ការប្រើប្រាស់យន្តការតុលាការដែលត្រូវបានគេចាត់ទុកថា នៅមិនទាន់មានឯករាជ្យទាំងស្រុង ប្រឆាំងនឹងអ្នកតំណាងរាស្ត្រ ដោយសារតែការបញ្ចេញមតិនឹងនាំឲ្យតួនាទីស្ថាប័នសភាក្នុងការឃ្លាំមើលរាជរដ្ឋាភិបាល និងភាពជាតំណាង ក្នុងការការពារ ផ្តល់ប្រយោជន៍ដល់ម្ចាស់ឆ្នោតកាន់តែខ្សោយថែមទៀត។

ក្នុងនីតិកាលទី៤នេះ អភ័យឯកសទ្ធិសភាដែលត្រូវបានផ្តល់ឲ្យសមាជិករដ្ឋសភាដើម្បីការពារខ្លួន ក្នុងការបំពេញភារកិច្ច

របស់ខ្លួន ជាពិសេសការបញ្ចេញមតិពីការគំរាមគំហែងដោយផ្លូវច្បាប់នោះត្រូវបានមើលឃើញថា មិនមានប្រយោជន៍ទាល់តែសោះក្នុងការការពារតំណាងរាស្ត្រ។ នេះក៏ដោយសារតែមានភាពងាយស្រួលខ្លាំងពេក ក្នុងការដកអភ័យឯកសិទ្ធិសភាពីអ្នកតំណាងរាស្ត្រ។

ចាប់ពីដើមនីតិកាលទី៤ រដ្ឋសភាបានធ្វើការដកអភ័យឯកសិទ្ធិសភាពីអ្នកតំណាងរាស្ត្រចំនួន៤លើក តាមការស្នើសុំរបស់តុលាការចំនួន៤ដង ឬមានន័យថា ឲ្យតែមានការស្នើសុំដកអភ័យឯកសិទ្ធិពីតុលាការ គឺរដ្ឋសភាបានយល់ព្រមទាំងអស់។

**********************************

ទិន្នន័យការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានប្រមូលមកពី៖ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលនីមួយៗ សាខាគណបក្សជាប់ឆ្នោតនីមួយៗនៅតាមខេត្ត គេហទំព័រ (website) របស់គណបក្ស ប្រព័ន្ធផ្សព្វផ្សាយ និង របាយការណ៍របស់អ្នកតំណាងរាស្ត្រ។

អ្នកតំណាងរាស្ត្រអាចផ្តល់ព័ត៌មានពីការចុះមូលដ្ឋានរបស់ខ្លួនតាមអស័យដ្ឋានដូចខាងក្រោម៖

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០/០១២ ៩៤២ ០១៩ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល៖ comfrel@online.com.kh គេហទំព័រ៖ www.comfrel.org